**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-May-2016, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកធ្វើជាភស្តុតាងនូវឯកសារមួយពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ALEXANDER LABAN HINTON (2-TCE-88)**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

Doreen CHEN

ព្រុំ ផល្លា

Marina HAKKOU

Léa KULINOWSKI

ឌី សុជាតា

**ចម្លងជូន៖**

**សហមេធាវីការពារក្ដី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") ដាក់សំណើនេះ ដើម្បីសុំឲ្យទទួលយកធ្វើជាភ័ស្តុតាងនូវឯកសារមួយដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់ Alexander Laban HINTON (2-TCE-88) ("លោក Hinton") និងពាក់ព័ន្ធនឹងភ័ស្តុតាងរបស់គាត់ជារួម។ ឯកសារដែលស្នើឡើងទាក់ទងទៅនឹងភាពមិនលម្អៀងរបស់លោក Hinton ដោយសារឯកសារនេះបង្ហាញថា គាត់មានបុរេវិនិច្ឆ័យរួចហើយពីពិរុទ្ធភាពរបស់លោក នួន ជា មុនពេលគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ។ ការទទួលយកឯកសារនេះធ្វើជាភ័ស្តុតាងនឹងអនុញ្ញាតឲ្យមេធាវីការពារក្តីអាចជំទាស់ទៅនឹងភាពអាចជឿជាក់បានរបស់លោក Hinton ហេតុនេះហើយ ឯកសារនេះមានប្រយោជន៍ក្នុងការស្វែងរកការពិត។

## II. ច្បាប់ជាធរមាន

2. រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ[1]។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភ័ស្តុតាង បើយល់ឃើញថា៖ មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា, មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ, មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង, ច្បាប់មិនអនុញ្ញាត, ឬ មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[2]។ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) ភ័ស្តុតាងដែលបានស្នើឡើងត្រូវតែមានភាពជាប់ពាក់ព័ន្ធ និងភាពជឿជាក់បាន *តាមការវិភាគបឋម* តែប៉ុណ្ណោះ[3]។ អនុលោមតាមវិធាន ៨៧(៤) ក្នុងដំណាក់កាលនានានៃការជំនុំជម្រះ ភាគីអាចស្នើសុំអង្គជំនុំជម្រះ "ទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមក

---

[1] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[2] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[3] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)" ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើតាមវិធាន ៨៧(៤)")។

នូវការស្វែងរកការពិត" ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣)[4]។ ទោះបីវិធាន ៨៧ (៤) ចែងថា ភស្តុតាងដែលបានស្នើសុំត្រូវតែមិនអាចរកបាននៅមុនពេលដំណើរការជំនុំជម្រះក៏ដោយ តែអង្គជំនុំជម្រះសាលាដំបូងបានបកស្រាយថា ភស្តុតាងក៏សំដៅដល់ភស្តុតាងដែលអាចរកបាននៅមុនពេលដំណើរការជំនុំជម្រះដែរ តែមិនត្រូវបានរកឃើញពីមុនបន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់[5]។

3. នៅក្នុងស្ថានភាពមួយចំនួន ភស្តុតាងដែលមិនបានបំពេញ "ទាំងស្រុង" ទៅនឹងលក្ខណវិនិច្ឆ័យនេះ ត្រូវបានទទួលយក នៅពេលដែលភស្តុតាងនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និងនៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវឲ្យយកប្រភពនានាមកវាយតម្លៃរួមគ្នា នៅពេលដែលភស្តុតាងដែលបានស្នើឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឲ្យវាយតម្លៃ ដើម្បីចៀសវាងភាពអយុត្តិធម៌ ឬនៅពេលដែលភាគីផ្សេងទៀតមិនជំទាស់ទៅនឹងភស្តុតាងនោះ[6]។

## III. ទឡ្ហីករណ៍

### ក. ទិដ្ឋភាពទូទៅ

4. ឯកសារដែលបានស្នើសុំគឺជាអត្ថបទកាសែតដែលមានចំណងជើងថា *Rutgers Professor Testifies at UN-backed trial of Senior Leaders of the Khmer Rouge (សាស្ត្រាចារ្យសាកលវិទ្យាល័យ Rutgers ផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះដែលគាំទ្រដោយអង្គការសហប្រជាជាតិ ទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម)* ដែលត្រូវបានចុះផ្សាយនៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ ដោយ Lawrence Lerner នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ Rutgers Today ("ឯកសារ")។

---

[4] មួយឆ្នាំបន្ទាប់ពីការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ អ.ជ.ស.ជ បានសម្រេចថា ភាគីត្រូវដាក់សំណើសុំឯកសារតាមវិធាន ៨៧(៤) ដែលមានក្នុងសំណុំរឿង តែមិនទាន់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីឯកសារដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយក ទោះបី ចុងក្រោយ សហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារទាំងនោះទៅក្នុងការដាក់ឯកសារបឋមក៏ដោយ *សូមមើល* សេចក្តីព្រាងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ២៤។

[5] ឯកសារ **E313** "សាលក្រមក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥, ឯកសារ **E289/2** សេចក្តីសម្រេចលើសំណើតាមវិធាន ៨៧(៤) កថាខណ្ឌ ៣។

[6] ឯកសារ **E289/2** សេចក្តីសម្រេចលើសំណើតាមវិធាន ៨៧(៤) កថាខណ្ឌ ៣។

ឯកសារនេះមាននៅក្នុង ***ឧបសម្ព័ន្ធ ១ សាធារណៈ***។ ឯកសារនេះសង្ខេបបទពិសោធន៍របស់លោក Hinton ក្នុងការផ្តល់សក្ខីកម្មនៅ អ.វ.ត.ក និងបង្ហាញពីការលើកឡើងនានារបស់គាត់ ក្រោយពេលផ្តល់សក្ខីកម្មនោះ។

5. ជាការសំខាន់ លោក Hinton បានលើកឡើងជាច្រើនដង ដែលបង្ហាញថា គាត់ពិតជាជឿថា លោក នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់។ នៅពេលពិពណ៌នាពីលោក នួន ជា មានការរាយការណ៍ថា លោក Hinton បាននិយាយថា៖

> [...] នេះហើយដែលជា**កំពូលឃាតករដ៏ល្បីល្បាញ ក្នុងចំណោមស្ថាបត្យករនៃអំពើប្រល័យពូជសាសន៍**[7]។

6. លោក Hinton បានលើកឡើងបែបចោទប្រកាន់បន្ថែមទៀតថា៖

> ខ្ញុំគិតថា [នួន ជា] នៅតែជឿជាក់លើចលនារបស់ពួកគេ និង**អ្វីដែលគាត់បានធ្វើ**[8]។

7. ចុងក្រោយ មានការរាយការណ៍ថា លោក Hinton បានសន្និដ្ឋានថា៖

> ជាការសំខាន់ដែលត្រូវចងចាំ [ថា នួន ជា ជាមនុស្ស] នៅពេលយើងពិចារណាទៅលើសោកនាដកម្មនេះ និង**ឧក្រិដ្ឋកម្ម ដែលគាត់ និងគូកនគាត់បានប្រព្រឹត្ត**[9]។

8. តាមរយៈការលើកឡើងទាំងនេះ លោក Hinton ផ្តល់ភ័ស្តុតាងយ៉ាងច្បាស់ថា គាត់បានមានបុរេវិនិច្ឆ័យរួចហើយទៅលើធាតុផ្សំសំខាន់នៃរឿងក្តីនេះ គឺ អត្ថិភាពនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មផ្សេងៗទៀត និងតួនាទីរបស់លោក នួន ជា នៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ការលើកឡើងទាំងនេះបង្ហាញថា លោក Hinton មានភាពលម្អៀង និងមិនបានផ្តល់ភ័ស្តុតាងអព្យាក្រឹត្យ និងមានលក្ខណៈសត្យានុម័ត ក្នុងអំឡុងពេលដែលគាត់ផ្តល់សក្ខីកម្មក្នុងសវនាការឡើយ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់សាក្សីជំនាញ ហេតុនេះ ត្រូវផ្តល់ទម្ងន់តិចតួច ប្រសិនបើត្រូវផ្តល់ ចំពោះភ័ស្តុតាងរបស់គាត់។

---

[7] គូសបញ្ជាក់បន្ថែម។

[8] គូសបញ្ជាក់បន្ថែម។

[9] គូសបញ្ជាក់បន្ថែម។

### ខ. ឯកសារមិនអាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះ និងគួរត្រូវបានទទួលយកធ្វើជាភស្តុតាងដើម្បីជាប្រយោជន៍នៃយុត្តិធម៌

9. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅខែ មិថុនា ឆ្នាំ ២០១១[10]។ ឯកសារនេះត្រូវបានបង្កើតឡើងក្រោយឆ្នាំ ២០១១ ហើយហេតុនេះមិនអាចរកបានមុនពេលចាប់ផ្តើមការជំនុំជម្រះទេ។ ជាងនេះទៀត ឯកសារនេះត្រូវបានចុះផ្សាយនៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ បន្ទាប់ពីលោក Hinton មកផ្តល់សក្ខីកម្មរួចហើយ ហេតុនេះឯកសារនេះមិនត្រូវបានបញ្ចូលទៅក្នុងសំណើរបស់មេធាវីការពារក្តីចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៦ សុំឱ្យទទួលយកធ្វើជាភស្តុតាងនូវឯកសារនានាទាក់ទិននឹងលោក Hinton ដើម្បីយកទៅប្រើប្រាស់នៅពេលមេធាវីការពារក្តីសួរដេញដោលទេ[11]។

10. ឯកសារនេះគឺជាការចុះផ្សាយដែលរាយការណ៍អំពីអ្វីដែលលោក Hinton បានលើកឡើង និងពាក់ព័ន្ធនឹងយោបល់ និងជំហររបស់គាត់ មិនត្រឹមតែចំពោះសក្ខីកម្មរបស់អ្នកជំនាញដែលគាត់បានផ្តល់នៅក្នុងសវនាការប៉ុណ្ណោះទេ តែរួមទាំងភស្តុតាងទាំងមូលរបស់គាត់ផង។ ហេតុនេះ ឯកសារនេះទាក់ទិននឹងតម្លៃជាភស្តុតាងនៃចម្លើយរបស់គាត់។ ហេតុនេះ ការទទួលយកឯកសារនេះបញ្ចូលក្នុងសំណុំរឿងមានប្រយោជន៍ក្នុងការស្វែងរកការពិត។

### គ. ឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២

11. លោក Hinton ត្រូវបានចាត់តាំងជាសាក្សីជំនាញដោយអង្គជំនុំជម្រះសាលាដំបូង ដោយគាត់មានកាតព្វកិច្ចផ្តល់សក្ខីកម្មទៅលើបញ្ហាទាំងអស់ដែលគាត់ដឹង និងមានជំនាញ ដោយមិនលម្អៀង និង

---

[10] ឯកសារ **E307/1** "សេចក្តីស្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ២។ ឯកសារ **E307/1/2** "សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេច*សាជាថ្មីឡើងវិញ*លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦។

[11] ឯកសារ **E387** "សំណើលើវិធាន ៨៧(៤) របស់ នួន ជា ស្នើសុំឱ្យទទួលយកឯកសារចំនួន ១៧ ទាក់ទងនឹងសក្ខីកម្មរបស់ Alexander Laban Hinton (2-TCE-88)" ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៦។

មានសត្យានុម័តបំផុត[12]។ ក្នុងនាមជាសាក្សីជំនាញ លោក Hinton មិនអាចបញ្ចេញយោបល់លើបញ្ហាអង្គហេតុស្នូលនានា[13] ដែលជាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង[14]។

12. យ៉ាងណាក៏ដោយ ដូចបានលើកឡើងខាងលើ ឯកសារនេះបង្ហាញថា លោក Hinton បានធ្វើសេចក្តីសន្និដ្ឋានរួចមកហើយទៅលើបញ្ហាជាសារវ័ន្តនានានៃរឿងក្តីនេះ គឺថា មានអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ហើយថា លោក នួន ជា ជា "ស្ថាបត្យករ" នៃអំពើនេះ។ ប្រការសំខាន់ ឯកសារនេះបញ្ជាក់ពីភាពលម្អៀងរបស់លោក Hinton ដែលបានបញ្ចេញឲ្យដឹងតាមរយៈសក្ខីកម្មរបស់គាត់នៅក្នុងសវនាការ នៅពេលគាត់ផ្តល់ចម្លើយជាច្រើនពាក់ព័ន្ធនឹងអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[15]។

13. ជាងនេះទៀត ចម្លើយនានានៅក្នុងឯកសារនេះបានលើកឡើងច្បាស់ថា លោក Hinton មានជំនឿ និងហាក់ដូចជាតែងតែមានជំនឿជាប្រចាំថា លោក នួន ជា ពិតជាមានពិរុទ្ធភាព។ ការមានជំនឿបែបនេះធ្វើឲ្យគាត់មិនអាចក្លាយជាសាក្សីជំនាញអព្យាក្រឹត្យ និងមានសត្យានុម័តទេ ហេតុនេះ វាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពជឿជាក់បានរបស់គាត់។ ហេតុនេះ បញ្ហានេះធ្វើឲ្យប៉ះពាល់ដល់ទម្ងន់ដែលត្រូវផ្តល់ដល់ភស្តុតាងរបស់គាត់ជារួម ប្រសិនបើត្រូវផ្តល់នោះ។

## ឃ. ឯកសារអាចជឿជាក់បាន និងមានយថាភាព

14. ឯកសារមានសញ្ញាណនៃអាចជឿជាក់បាន*តាមការវិភាគបឋម*។ ឯកសារនេះត្រូវបានចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយ Rutgers Today ដែលជាប្រព័ន្ធផ្សព្វផ្សាយលើបណ្តាញអ៊ីនធឺណេត ដែលជាប្រភពព័ត៌មាន និងដំណឹងផ្លូវការទាក់ទិននឹងសាកលវិទ្យាល័យ Rutgers-Newark (ស.វ.អា)

---

[12] ឯកសារ **E215** "សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ" ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើអ្នកជំនាញ") កថាខណ្ឌ ១៥។

[13] ឯកសារ **E215** សេចក្តីសម្រេចលើអ្នកជំនាញ កថាខណ្ឌ ១៦។

[14] ឯកសារ **E215** សេចក្តីសម្រេចលើអ្នកជំនាញ កថាខណ្ឌ ១៦។

[15] ឯកសារ **E1/401.1** ទំព័រ ១៨ ម៉ោង ១០:០៧:៤០, ឯកសារ **E1/402.1** ទំព័រ ៦ ម៉ោង ០៩:១៨:៥៥, ទំព័រ ៣១ ម៉ោង ១១:០០:៤៥, ទំព័រ ៧២ ម៉ោង ១៥:៣៧:៤៧, ទំព័រ ៧៦ ម៉ោង ១៥:៥០:០៤, ឯកសារ **E1/403.1** ទំព័រ ៣៥ ម៉ោង ១១:១៥:៤០, ទំព័រ ៣៨ ម៉ោង ១១:២៣:០៦, ទំព័រ ៥៥ ម៉ោង ១៤:១២:៤៤, ទំព័រ ៦៤ ម៉ោង ១៤:៤៥:២៩, ទំព័រ ៧២ ម៉ោង ១៥:៣០:៥០, ឯកសារ **E1/404.1** ទំព័រ ៤១ ម៉ោង ១១:៤១:០៨, ទំព័រ ៤៨ ម៉ោង ១២:០៨:៥២។

ដែលលោក Hinton ជាសាស្ត្រាចារ្យនៅទីនោះ។

## IV. **សំណូមពរ**

15. ផ្អែកតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យទទួលយកឯកសារនេះធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ Victor KOPPE